**MEDIA ADVISORY**

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# សិទ្ធិមនុស្ស៖ ដំណើរទស្សនកិច្ចរបស់អ្នករាយការណ៍ពិសេស អ.ស.ប ទៅកាន់ប្រទេសកម្ពុជា ត្រូវបានលើកពេល

ទីក្រុងហ្សឺណែវ / រាជធានីភ្នំពេញ (១៨ ឧសភា ២០១៥) - បេសកកម្មទៅកាន់ប្រទេសកម្ពុជារបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកស្រី រ៉ូណា ស្មីត ត្រូវបានលើកពេលដោយសារតែមានភាពលំបាកខាងភ័ស្តុភារ និងរដ្ឋបាល។

ជំនាញការឯករាជ្យដែលទើបតែងតាំងថ្មីរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស កន្លងមកបានគ្រោងធ្វើដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ សម្រាប់បេសកកម្មស្វែងរកការពិតលើកដំបូង។

សេចក្តីប្រកាសព័ត៌មានថ្មីមួយនឹងត្រូវចេញផ្សាយភ្លាមៗនៅពេលដែលបេសកកម្មរបស់លោកស្រីត្រូវបានកំណត់ពេលវេលាជាថ្មីឡើងវិញ។

នេះគឺដើម្បីជាដំណើរទស្សនកិច្ចជាលើកដំបូងមកកាន់ប្រទេសកម្ពុជារបស់អ្នករាយការណ៍ពិសេសដែលទើបតែងតាំងថ្មីរូបនេះ។ អាណត្តិបង្កើតមុខងារឃ្លាំមើលមួយដែលត្រូវបានធ្វើឡើងតាមរយៈដំណើរទស្សនកិច្ច ឬបេសកកម្មជាទៀងទាត់មកកាន់ប្រទេសកម្ពុជា តាមការអញ្ជើញរបស់រដ្ឋាភិបាល និងលក្ខខណ្ឌតម្រូវក្នុងការធ្វើរបាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស។ លោកស្រី ស្មីត រំពឹងថានឹងដាក់របាយការណ៍ដំបូងរបស់លោកស្រីជូនក្រុមប្រឹក្សានេះក្នុងខែកញ្ញាឆ្នាំ ២០១៥។

ចប់

*សាស្ត្រាចារ្យ* ***រ៉ូណា ស្មីត*** *(ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ តែងតាំង ក្នុងខែមីនា ឆ្នាំ២០១៥ ដើម្បីស្នងដំណែងរបស់លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ដែលបានបញ្ចប់អាណត្តិប្រាំមួយឆ្នាំ ក្នុងខែមីនា ឆ្នាំ២០១៥។ អាណត្តិរបស់អ្នករាយការណ៍ពិសេសនេះ កើតចេញកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ស្តីពីដំណោះស្រាយនយោបាយទូលំទូលាយនៃជម្លោះកម្ពុជា។ លោកស្រី ស្មីត គឺជាសាស្ត្រាចារ្យផ្នែកសិទ្ធិមនុស្សអន្តរជាតិនៅចក្រភពអង់គ្លេស។ លោកស្រី ស្មីត ក៏ជាសាស្ត្រាចារ្យទស្សនកិច្ចនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រក្នុងប្រទេសកម្ពុជា ជាសាកលវិទ្យាល័យដែលលោកស្រីបានធ្វើការរៀបចំ និងបង្កើតកម្មវិធីសិក្សា ដើម្បីប្រកាសបើកឡើងវិញនូវកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើកដំបូងរបស់កម្ពុជាផ្នែកច្បាប់សិទ្ធិមនុស្ស។*

*អ្នករាយកាណ៍ពិសេសគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃជំនាញការឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលលើកអំពីស្ថានភាពរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាតាមវិស័យនីមួយៗនៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ជំនាញការរបស់នីតិវិធីពិសេស ធ្វើការឈរលើគោលការណ៍*

*ស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ពួកគាត់ដែរ។ ពួកគាត់ធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ពួកគាត់។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា*
*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx and http://cambodia.ohchr.org*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទងមក ៖*
***នៅរាជធានីភ្នំពេញ៖** លោកស្រី ប៊ូស្រា រ៉ាម៉ាន់ (Ms. Bushra Rahman) តាមរយៈទូរស័ព្ទលេខ (+៨៥៥ ១២ ៧៩០ ១៧៨ / អ៊ីម៉េល brahman@ohchr.org)*
***នៅទីក្រុងហ្សឺណែវ៖** លោកស្រី អ័លហ្គា ណាកាចូ (Ms. Olga Nakajo) តាមរយៈទូរស័ព្ទលេខ (+៤១ ៧៩១០៩៦៨៧២ ឬ +៤១ ១២៧៧៧៨៣១ / អ៊ីមែល onakajo@ohchr.org) ឬ សរសេរមកកាន់ srcambodia@ohchr.org*

សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖
សាប៊ៀរ សេលាយ៉ា (Xabier Celaya) អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីមែល xcelaya@ohchr.org)

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម៖**
**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights និង https://www.facebook.com/OHCHRCambodia
**ទ្វីតធឺ៖** http://twitter.com/UNrightswire និង http://twitter.com/OHCHR_Cambodia
**ហ្គោហ្គលឺ៖ Google+** gplus.to/unitednationshumanrights
**យូធូប៖** http://www.youtube.com/UNOHCHR
**បរិយាយសាច់រឿង ៖** http://storify.com/UNrightswire

ផែកលិបិក្រមសិទ្ធិមនុស្សជាសកល ៖ http://uhri.ohchr.org/en